# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងរដ្ឋប្បវេណី
លេខ: ២៤៥
ចុះថ្ងៃទី ២៨-៦-២០១២
សាលដីកា
លេខ: ២១ ក្រ៥.ប
ចុះថ្ងៃទី ២៨-៦-២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

រវាងដើមចោទឈ្មោះ [redacted] គឹមថា ភេទស្រី អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីលំនៅផ្ទះលេខ $29E_1$ ផ្លូវលេខ ៥៥៤ ក្រុម៣៧ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឯក (រ) ម្តាយឈ្មោះ [redacted] ធំ (រ) ប្តីឈ្មោះ [redacted] ប៊ុនយ៉ន ។

- មានមេធាវីតំណាងដោយអាណត្តិលោក [redacted]

និងសហចុងចម្លើយ:

១- ឈ្មោះ [redacted] សាវ៉ែន ភេទស្រី អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ នៅផ្ទះ មានទីលំនៅផ្ទះលេខ $29E_0$ ផ្លូវលេខ ៥៥៤ ក្រុម៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានី ភ្នំពេញ ឪពុកឈ្មោះ [redacted] ចាន់ (ស) ម្តាយឈ្មោះ [redacted] សុខ (ស) ប្តីឈ្មោះ [redacted] សាវិន មានកូន ០៣នាក់ ។

២- ឈ្មោះ [redacted] សុភាលី ភេទស្រី អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅផ្ទះលេខ $29E_0$ ផ្លូវលេខ ៥៥៤ ក្រុម៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ជឹម (ស) ម្តាយឈ្មោះ [redacted] ណារ (ស) ប្តីឈ្មោះ [redacted] វណ្ណា មានកូន ០២នាក់ ។

៣- ឈ្មោះ [redacted] ចាន់ណារី ភេទស្រី អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅផ្ទះលេខ $29E_0$ ផ្លូវលេខ ៥៥៤ ក្រុម៣៧ សង្កាត់បឹងកក់១



Scanned with CamScanner

ខណ្ឌទួលគោក រាជធានី ភ្នំពេញ ឪពុកឈ្មោះ [redacted] ទុំ (ស). ម្តាយឈ្មោះ [redacted] សុខន (ស) ប្តីឈ្មោះ [redacted] សីឌី មានកូន ០២ នាក់ ។

**កម្មវត្ថុបណ្តឹង:**

ប្តឹងសុំឲ្យតុលាការចេញសាលក្រមឲ្យចុងចម្លើយរុះរើរបងស័ង្កសីដែលហ៊ុំព័ទ្ធលើដី មាន ទំនាស់ទំហំ ៥.៨០ម៉ែត្រ x ៦.៨០ម៉ែត្រ ស្ថិតនៅដីឡូតិ៍លេខ ២៩ ក្រុម៣៧ ផ្លូវលេខ ៥៥៤ សង្កាត់ បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**អង្គហេតុ និងចំណុចខទាន:**

+ ការទាមទាររបស់ដើមចោទ:

- ដើមចោទឈ្មោះ [redacted] គឺមថា ប្តឹងសុំឲ្យតុលាការចេញសាលក្រមឲ្យចុងចម្លើយរុះរើរបង ស័ង្កសីចេញដែលហ៊ុំព័ទ្ធលើដីកំពុងមានទំនាស់ឲ្យដីនៅសភាពដើមដដែលរង់ចាំរកម្ចាស់កម្មសិទ្ធិពិតប្រាកដសិន ។

+ ចំណុចវិវាទ:

- ដើមចោទ:សុំឲ្យចុងចម្លើយរុះរើរបងស័ង្កសីដែលហ៊ុំព័ទ្ធលើដីចេញដោយទុកឲ្យនៅសភាពដើមដដែល រីឯចុងចម្លើយមិនព្រមរុះរើចេញទេ ដោយសុំទុកការហ៊ុំព័ទ្ធស័ង្កសីជាបណ្តោះអាសន្នសិនជៀសវាងការមានទំនាស់ ព្រោះដីនេះមិនទាន់មានម្ចាស់កម្មសិទ្ធិនៅឡើយ ។

- ការអះអាងរបស់ដើមចោទ: ដើមចោទឈ្មោះ [redacted] គឺមថា បានថ្លែងការណ៍ថា ឈ្មោះ [redacted] សារឿន បានលក់ពាក់កណ្តាល ហើយបានបិទទុកតែ ៥ម៉ែត្រ ឲ្យដើរទៅខាងក្រោយ ។ ដីនេះលក់ឲ្យគេជ្រេង ខ្លួនមិនដឹងទេ ពេលខ្លួនជួសជុលទើបមានឈ្មោះបីគ្រួសារនេះជំទាស់ ក្រោយពីខ្លួនធ្វើកម្មសិទ្ធិទើបមានបញ្ហានេះកើតឡើង ចំពោះដីនេះរួមជាមួយតែឈ្មោះ [redacted] សារឿន ទេ ។ សុំឲ្យតុលាការរកយុត្តិធម៌ឲ្យខ្លួន ខ្លួនសុំរក្សាសភាពដើមចំពោះដីដែលមានទំនាស់នេះ ខ្លួនសុំរុះរើសំណង់ចេញពីដីនេះរង់ចាំការសម្រេចសេចក្តីរបស់តុលាការសិន ។ សូមបញ្ជាក់ថាឈ្មោះ [redacted] សារឿន លក់ដីឲ្យអ្នកទាំងបីនេះ ។

- លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានថ្លែងការណ៍ថា ដីនេះកូនក្តីខ្លួនបានគ្រប់គ្រងតាំងពីឆ្នាំ ១៩៨៥ ។ នៅឆ្នាំ ១៩៩២ រហូតដល់ឆ្នាំ ២០០៩ ឈ្មោះ [redacted] ចាន់ណារី, ឈ្មោះ [redacted] សុភាលី និងឈ្មោះ [redacted] សារ៉ែន បានផ្ទេរសិទ្ធិឲ្យជំទាវ [redacted] ដារ៉ា បន្តរឿងក្តីជាមួយកូនក្តីខ្លួន បន្ទប់ដែលកូនក្តីខ្លួនធ្លាប់គ្រប់គ្រងបែរជាភាគីម្ខាងនៅតែរំលោភយកធ្វើសំណង់ទៅវិញ ។ សំណូមពរ សុំឲ្យសាលាឧទ្ធរណ៍សម្រេចឡើងវិញចំពោះបណ្តឹងរបស់កូនក្តីខ្លួន ។

- ការអះអាងរបស់ចុងចម្លើយ: ចុងចម្លើយឈ្មោះ [redacted] ចាន់ណារី បានថ្លែងការណ៍ថា ប៉ូលីសចុះរុះរើហើយកូនស្រីគាត់ពីនាក់ដីករបងធ្វើឡើងវិញ រឿងបិទរបងនេះមានប៉ូលីសចូលរួមជាអ្នកឲ្យបិទ អណ្តូងទឹកប្រើរួមទាំងអស់គ្នា ។ ខ្លួនមកនៅក្រោយឈ្មោះ [redacted]



Scanned with CamScanner

គឹមថា ។ ខ្លួនទិញដីនេះពីឈ្មោះ [redacted] សារ៉ន ក្រោយពីឈ្មោះគ្នារួចហើយទើបខ្លួនបិទ ។ អ្នកនៅលើពីរគ្រួសារ គាត់ឈ្មោះ [redacted] គឹមថា ។ សព្វថ្ងៃនេះខ្លួនលក់ឲ្យគេអស់ហើយ ។

**សាលាឧទ្ធរណ៍យល់ឃើញថាៈ**

១- បណ្ដឹងឧទ្ធរណ៍លេខ ៦១ ចុះថ្ងៃទី២៩-០២-២០១២ របស់ដើមចោទឈ្មោះ [redacted] គឹមថា ប្ដឹងគ្រង់ចំណុច ទាំងមូលនៃសេចក្ដីសម្រេចរបស់សាលក្រម បណ្ដឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍ទទួលចាត់ការតាមនីតិវិធី ។

២- ការដែលដើមចោទឈ្មោះ [redacted] គឹមថា ដោយមានមេធាវី [redacted] តំណាងដោយអាណត្តិបានថ្លែងការណ៍នៅចំពោះមុខសាលាឧទ្ធរណ៍ថា ខ្លួននៅតែរក្សាទុកសេចក្ដីថ្លែងការណ៍របស់ខ្លួនដែលថ្លែងនៅសាលាដំបូងរាជធានីភ្នំពេញនៅដដែល ដោយស្នើសុំឲ្យតុលាការចេញសាលដីកាឲ្យភាគីចុងចម្លើយរុះរើរបងស័ង្កសីចេញពីដីទំហំ ៥.៨០ម៉ែត្រ x ៦.៨០ម៉ែត្រ ស្ថិតនៅដីឡូត៍លេខ ២៩ ក្រុម ៣៧ ផ្លូវលេខ ៥៥៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញនោះ ពុំទាន់មានលក្ខណៈសមស្របតាមច្បាប់នៅឡើយ ដោយហេតុថា ដីទំនាស់ដែលមានទំហំ និងទីតាំងដូចខាងលើ គូភាគីទទួលស្គាល់ថា ជាដីទុកសម្រាប់ប្រើប្រាស់រួមគ្នាជាច្រើនគ្រួសារ ប៉ុន្តែភាគីដើមចោទធ្វើការបិទបាំងដោយជញ្ជាំងឥដ្ឋជាបន្ទប់ៗ ប្រើប្រាស់ម្នាក់ឯង ដែលជាហេតុនាំឲ្យមានការស្នើសុំឲ្យតុលាការចេញដីកាសម្រេចរក្សាការពាររុះរើបន្ទប់ទាំងនោះចេញ ហើយតុលាការបានចុះអនុវត្តរួចហើយដែរ ម្យ៉ាងទៀតនៅចំពោះមុខសាលាឧទ្ធរណ៍គូភាគីបានបង្ហាញភស្តុតាងជាឯកសារ និងរូបថតដែលពាក់ព័ន្ធឃើញថា គ្រប់គ្នាសុទ្ធតែប្រើប្រាស់ដីទំនាស់ខាងលើជាប្រយោជន៍រៀងៗខ្លួន។

៣- តាមការបញ្ជាក់របស់ភាគីចុងចម្លើយថា ពួកខ្លួនបានរួមគ្នាចាក់ដីអស់ជាច្រើនឡាន ដូចនេះជៀសវាងមានទំនាស់កើតឡើង និងប៉ះពាល់ដល់ប្រយោជន៍រួមកាន់តែធ្ងន់ធ្ងរ គប្បីអនុញ្ញាតឲ្យភាគីចុងចម្លើយគ្រប់គ្រងដីទំនាស់ខាងលើទៅតាមច្បាប់ ។

៤- សំអាងហេតុ និងសេចក្ដីសម្រេចនៃសាលក្រមរដ្ឋប្បវេណីលេខ ០៧(គ) ចុះថ្ងៃទី ០៩-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដី**

១- ច្រានចោលបណ្ដឹងឧទ្ធរណ៍លេខ ៦១ ចុះថ្ងៃទី២៩-០២-២០១២ របស់ដើមចោទឈ្មោះ [redacted] គឹមថា ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៧ (គ) ចុះថ្ងៃទី០៩-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។



Scanned with CamScanner

៨-សាលដីកានេះទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី១២-៦-២០១៣ និងប្រកាសជាសាធារណៈ ថ្ងៃទី២៨-៦-២០១៣ ។

- បើកផ្លូវប្តឹងសាទុក្ខក្នុងរយៈពេល ០១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |

ហត្ថលេខា: [redacted]

---

| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| --- | --- |
| ប្រធានក្រុមប្រឹក្សា | ភ្នំពេញ,ថ្ងៃទី[illegible]ខែ[illegible]...ឆ្នាំ ២០១៣ |
| | ក្រឡាបញ្ជី |
| [redacted] | [redacted] |